ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ៥៧០ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការកាត់ដីទំហំ ៣៨០,៧២ ហិកតា នៅក្នុង ស្រុកត្រាំកក់ ខេត្តតាកែវ ចេញពីគម្របព្រៃឈើ ឆ្នាំ ២០០២ ដើម្បីធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋសម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និង រក្សាទុកមួយចំណែកជាដីសាធារណៈរបស់រដ្ឋ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២នសចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៨ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីព្រៃឈើ



6

www.pheakdeylaw.com

- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋនិងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី០១ខែវិច្ឆិកាឆ្នាំ១៩៩៣ស្តីពីការបង្កើតនិងការកំណត់តំបន់ការពារធម្មជាតិ
- បានឃើញអនុក្រឹត្យលេខ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ៨៨ អនក្រ.បក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០០ ស្តីពីការបង្កើតក្រុមប្រឹក្សាគោលនយោបាយដីធ្លី
- បានឃើញអនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញអនុក្រឹត្យលេខ១៤៦ អនក្រ.បកចុះថ្ងៃទី២៧ខែធ្នូ ឆ្នាំ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច
- បានឃើញសារាចរលេខ ០២ សរ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៧ ស្តីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់
- បានឃើញលិខិតលេខ០១៣ ស.ណ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០១៣ របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តតាកែវ
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

# សម្រេច

**មាត្រា ១.-**

ត្រូវបានកាត់ដីទំហំ ៣៨០,៧២ ហិកតា ចេញពីគម្របព្រៃឈើឆ្នាំ ២០០២ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋទំហំ សម្រាប់ធ្វើប្រទានកម្ម ទំហំ ៣៤៧,៧៨ ហិកតា ជាកម្មសិទ្ធិជូនប្រជាពលរដ្ឋដែលបានកាន់កាប់ប្រើប្រាស់និងដាំដុះជាក់ស្តែង និងរក្សាទុក ទំហំ ៣២,៩៤ ហិកតា ជាដីសាធារណៈរបស់រដ្ឋ នៅឃុំ ត្រពាំងធំខាងត្បូង ស្រុកត្រាំកក់ ខេត្តតាកែវ ស្ថិតនៅក្នុងភូមិ ដូចខាងក្រោម៖

- ផ្ទៃដីទំហំ ៩៩,៣៣ ហិកតាកាត់ចេញពីគម្របព្រៃឈើឆ្នាំ២០០២ សម្រាប់ប្រទានកម្ម ទំហំ ៩១,០៣ ហិកតា ជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងរក្សាទុក ទំហំ ៣,៣០ ហិកតា ជាដីសាធារណៈរបស់រដ្ឋ នៅភូមិត្រពាំងកោះ
- ផ្ទៃដីទំហំ ១៤,១២ ហិកតា កាត់ចេញពីគម្របព្រៃឈើឆ្នាំ២០០២ សម្រាប់ប្រទានកម្ម ទំហំ ១០,៩៥ ហិកតា ជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងរក្សាទុក ទំហំ ៣,១៧ ហិកតា ជាដីសាធារណៈរបស់រដ្ឋ នៅភូមិព្រៃក្តី
- ផ្ទៃដីទំហំ ៣៥,៤៣ ហិកតា កាត់ចេញពីគម្របព្រៃឈើឆ្នាំ២០០២ សម្រាប់ប្រទានកម្ម ទំហំ ៣២,៥៤ ហិកតា ជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងរក្សាទុក ទំហំ ២,៨៩ ហិកតា ជាដីសាធារណៈរបស់រដ្ឋ នៅភូមិត្រពាំងជ្រៃ



www.pheakdeylaw.com

- ផ្ទៃដីទំហំ ៨៨,៧៧ ហិកតា កាត់ចេញពីគម្របព្រៃឈើឆ្នាំ២០០២ សម្រាប់ប្រទានកម្ម ទំហំ ៨៣,៨០ ហិកតា ជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងរក្សាទុក ទំហំ ៤,៩៧ ហិកតា ជាដីសាធារណៈ របស់រដ្ឋ នៅភូមិត្រពាំងសោម
- ផ្ទៃដីទំហំ ៣៩,៣៧ ហិកតា កាត់ចេញពីគម្របព្រៃឈើឆ្នាំ២០០២ សម្រាប់ប្រទានកម្ម ទំហំ ៣៧,០៣ ហិកតា ជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងរក្សាទុក ទំហំ ២,៣៤ ហិកតា ជាដីសាធារណៈ របស់រដ្ឋ នៅភូមិត្រពាំងឈូក
- ផ្ទៃដីទំហំ ៣៨,៥៤ ហិកតា កាត់ចេញពីគម្របព្រៃឈើឆ្នាំ២០០២ សម្រាប់ប្រទានកម្ម ទំហំ ៣២ ហិកតា ជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងរក្សាទុក ទំហំ ៦,៥៤ ហិកតា ជាដីសាធារណៈរបស់រដ្ឋ នៅភូមិត្រពាំងប្រីយ៍
- ផ្ទៃដីទំហំ ១២០,១៦ ហិកតា កាត់ចេញពីគម្របព្រៃឈើឆ្នាំ២០០២ សម្រាប់ប្រទានកម្ម ទំហំ ១១០,៨៣ ហិកតា ជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងរក្សាទុក ទំហំ ៩,៧៣ ហិកតា ជាដីសាធារណៈ របស់រដ្ឋ នៅភូមិព្រៃព្រាល

តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum wgs 1984 និងមាននិយាមកា ដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ ។

**មាត្រា ២.-**

ត្រូវបានប្រគល់អាណត្តិកាន់កាប់ និងបែងចែកដីរបស់រដ្ឋ ដូចមានចែងក្នុងមាត្រា១ ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តតាកែវ ធ្វើការគ្រប់គ្រង និងប្រទានកម្មជាកម្មសិទ្ធិឯកជនជូនប្រជាពលរដ្ឋ ចំនួន ៣៩២ គ្រួសារ ដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្តែង នៅឃុំត្រពាំងធំខាងត្បូង ស្រុកត្រាំកក់ ខេត្តតាកែវ ក្នុងភូមិ ដូចខាងក្រោម៖

-ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ៦៧គ្រួសារ នៅភូមិត្រពាំងកោះ
-ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ២៥គ្រួសារ នៅភូមិព្រៃក្តី
-ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ៩១គ្រួសារ នៅភូមិត្រពាំងជ្រៃ
-ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ៨៣គ្រួសារ នៅភូមិត្រពាំងសោម
-ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ៤៥គ្រួសារ នៅភូមិត្រពាំងឈូក
-ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ៣២គ្រួសារ នៅភូមិត្រពាំងប្រីយ៍
-ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ១០០គ្រួសារ នៅភូមិព្រៃព្រាល ។

**មាត្រា ៣.-**

ក្នុងពេលដំណើរការវាស់វែង និងបែងចែកជាក់ស្តែង គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តតាកែវ ត្រូវកាត់ចេញនូវចំណែកដីមួយចំនួនសមស្រប ដើម្បីរក្សាទុកសម្រាប់បម្រើផលប្រយោជន៍សាធារណៈ ជាអាទិ៍ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងសង្គមនៅក្នុងមូលដ្ឋាន។



www.pheakdeylaw.com

**មាត្រា ៤.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៥.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តតាកែវ ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញថ្ងៃទី ២១ ខែកុម្ភៈ ឆ្នាំ២០១៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល៖

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការ រាជរដ្ឋាភិបាល*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា*
- *អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៥*
- *រាជកិច្ច*
- *ឯកសារកាលប្បវត្តិ*



www.pheakdeylaw.com

ឧបសម្ព័ន្ធ........នៃអនុក្រឹត្យលេខ ៣៤ អនក.បក ចុះថ្ងៃទី ០២ ខែ មីនា ឆ្នាំ២០១៣ ស្តីពីអនុបយោគកាត់ដីចេញពីគម្រូបព្រៃឈើឆ្នាំ២០០២ នៅស្រុកត្រាំកក់ ខេត្តតាកែវ ទូទំផ្ទៃដីទំហំ ៣៨០.៧២ ហិចតា ជាដីឯកជនរបស់រដ្ឋ ដើម្បីធ្វើប្រទានកម្មជូនប្រជាពលរដ្ឋដែលបាន កាន់កាប់ប្រើប្រាស់ និងដាំដុះជាក់ស្តែងផ្ទៃដីទំហំ ៣៤៧.៧៨ហិចតា និងរក្សាទុកជាដីសាធារណៈរបស់រដ្ឋផ្ទៃដីទំហំ ៣២.៩៤ហិចតា




| ចំណុចនិយាមកា | | | | | |
|---|---|---|---|---|---|
| ចំណុច | X | Y | ចំណុច | X | Y |
| 1 | 447992 | 1220142 | 45 | 449867 | 1216899 |
| 2 | 448121 | 1220159 | 46 | 449920 | 1217199 |
| 3 | 448118 | 1220221 | 47 | 449900 | 1217312 |
| 4 | 448343 | 1220218 | 48 | 449847 | 1217398 |
| 5 | 448324 | 1220398 | 49 | 449820 | 1217577 |
| 6 | 448415 | 1220414 | 50 | 449740 | 1217580 |
| 7 | 448463 | 1220435 | 51 | 449707 | 1217681 |
| 8 | 448610 | 1220453 | 52 | 449731 | 1217847 |
| 9 | 448831 | 1220268 | 53 | 449630 | 1217833 |
| 10 | 449436 | 1219696 | 54 | 449537 | 1217862 |
| 11 | 449609 | 1219538 | 55 | 449407 | 1217813 |
| 12 | 449883 | 1219169 | 56 | 449376 | 1217950 |
| 13 | 449954 | 1218946 | 57 | 449335 | 1218054 |
| 14 | 450022 | 1218578 | 58 | 449307 | 1218165 |
| 15 | 450032 | 1218314 | 59 | 449214 | 1218159 |
| 16 | 450080 | 1218150 | 60 | 449226 | 1218302 |
| 17 | 450316 | 1217692 | 61 | 449217 | 1218452 |
| 18 | 450512 | 1217390 | 62 | 449240 | 1218572 |
| 19 | 450868 | 1216705 | 63 | 449120 | 1218571 |
| 20 | 451423 | 1215720 | 64 | 449019 | 1218606 |
| 21 | 451451 | 1215625 | 65 | 449030 | 1218673 |
| 22 | 451308 | 1215600 | 66 | 449120 | 1218711 |
| 23 | 451163 | 1215552 | 67 | 449111 | 1218861 |
| 24 | 450936 | 1215517 | 68 | 449006 | 1218939 |
| 25 | 450831 | 1215601 | 69 | 448908 | 1218966 |
| 26 | 450711 | 1215599 | 70 | 448899 | 1219077 |
| 27 | 450528 | 1215561 | 71 | 448822 | 1219062 |
| 28 | 450510 | 1215671 | 72 | 448798 | 1219132 |
| 29 | 450556 | 1215748 | 73 | 448855 | 1219226 |
| 30 | 450581 | 1215890 | 74 | 448771 | 1219202 |
| 31 | 450674 | 1215952 | 75 | 448742 | 1219197 |
| 32 | 450503 | 1215973 | 76 | 448742 | 1219291 |
| 33 | 450365 | 1215923 | 77 | 448825 | 1219327 |
| 34 | 450339 | 1216079 | 78 | 448766 | 1219435 |
| 35 | 450512 | 1216125 | 79 | 448724 | 1219423 |
| 36 | 450487 | 1216291 | 80 | 448674 | 1219492 |
| 37 | 450507 | 1216524 | 81 | 448693 | 1219561 |
| 38 | 450375 | 1216466 | 82 | 448644 | 1219554 |
| 39 | 450244 | 1216500 | 83 | 448659 | 1219691 |
| 40 | 450282 | 1216629 | 84 | 448652 | 1219794 |
| 41 | 450016 | 1216546 | 85 | 448545 | 1219849 |
| 42 | 449749 | 1216614 | 86 | 448283 | 1219844 |
| 43 | 449659 | 1216767 | 87 | [illegible] | [illegible] |

ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ.៧៧ អនក្រ.បក ចុះថ្ងៃទី.២១.....ខែកុម្ភៈ....ឆ្នាំ២០១៣

ស្តីពីការកាត់ដីទំហំ ៣៨០.៧២ហិចតា ចេញពីផែនទីតម្រុយព្រៃឈើឆ្នាំ២០០២ ក្នុងនោះស្នើសុំធ្វើអនុបយោគ ជាដីឯកជនរបស់រដ្ឋ និង ការធ្វើប្រទានកម្ម ទំហំ ៣៤៧.៧៨ហិចតា ជូនប្រជាពលរដ្ឋចំនួន ៣៩២គ្រួសារកាន់កាប់ប្រើប្រាស់ និង រក្សាទុកទំហំ ៣២.៩៤ហិចតា ជាដីសាធារណៈរបស់រដ្ឋ ស្ថិតនៅភូមិព្រៃភ្លី ភូមិត្រពាំងកោះ ភូមិត្រពាំងជ្រៃ ភូមិត្រពាំងប្រិយ៍ ភូមិត្រពាំងឈូក ភូមិត្រពាំងសោម និង ភូមិព្រៃព្រាល ឃុំត្រពាំងធំខាងត្បូង ស្រុកត្រាំកក់ ខេត្តតាកែវ




| ចំណុចនិយាមកា | | | | | |
|---|---|---|---|---|---|
| ចំណុច | X | Y | ចំណុច | X | Y |
| 1 | 447992 | 1220142 | 45 | 449867 | 1216899 |
| 2 | 448121 | 1220159 | 46 | 449920 | 1217199 |
| 3 | 448118 | 1220221 | 47 | 449900 | 1217312 |
| 4 | 448343 | 1220218 | 48 | 449847 | 1217398 |
| 5 | 448324 | 1220398 | 49 | 449820 | 1217577 |
| 6 | 448415 | 1220414 | 50 | 449740 | 1217580 |
| 7 | 448463 | 1220435 | 51 | 449707 | 1217681 |
| 8 | 448610 | 1220453 | 52 | 449731 | 1217847 |
| 9 | 448831 | 1220268 | 53 | 449630 | 1217833 |
| 10 | 449436 | 1219696 | 54 | 449537 | 1217862 |
| 11 | 449609 | 1219538 | 55 | 449407 | 1217813 |
| 12 | 449883 | 1219169 | 56 | 449376 | 1217950 |
| 13 | 449954 | 1218946 | 57 | 449335 | 1218054 |
| 14 | 450022 | 1218578 | 58 | 449307 | 1218165 |
| 15 | 450032 | 1218314 | 59 | 449214 | 1218159 |
| 16 | 450080 | 1218150 | 60 | 449226 | 1218302 |
| 17 | 450316 | 1217692 | 61 | 449217 | 1218452 |
| 18 | 450512 | 1217390 | 62 | 449240 | 1218572 |
| 19 | 450868 | 1216705 | 63 | 449120 | 1218571 |
| 20 | 451423 | 1215720 | 64 | 449019 | 1218606 |
| 21 | 451451 | 1215625 | 65 | 449030 | 1218673 |
| 22 | 451308 | 1215600 | 66 | 449120 | 1218711 |
| 23 | 451163 | 1215552 | 67 | 449111 | 1218861 |
| 24 | 450936 | 1215517 | 68 | 449006 | 1218939 |
| 25 | 450831 | 1215601 | 69 | 448908 | 1218966 |
| 26 | 450711 | 1215599 | 70 | 448899 | 1219077 |
| 27 | 450528 | 1215561 | 71 | 448822 | 1219062 |
| 28 | 450510 | 1215671 | 72 | 448798 | 1219132 |
| 29 | 450556 | 1215748 | 73 | 448855 | 1219226 |
| 30 | 450581 | 1215890 | 74 | 448771 | 1219202 |
| 31 | 450674 | 1215952 | 75 | 448742 | 1219197 |
| 32 | 450503 | 1215973 | 76 | 448742 | 1219291 |
| 33 | 450365 | 1215923 | 77 | 448825 | 1219327 |
| 34 | 450339 | 1216079 | 78 | 448766 | 1219435 |
| 35 | 450512 | 1216125 | 79 | 448724 | 1219423 |
| 36 | 450487 | 1216291 | 80 | 448674 | 1219492 |
| 37 | 450507 | 1216524 | 81 | 448693 | 1219561 |
| 38 | 450375 | 1216466 | 82 | 448644 | 1219554 |
| 39 | 450244 | 1216500 | 83 | 448659 | 1219691 |
| 40 | 450282 | 1216629 | 84 | 448652 | 1219794 |
| 41 | 450016 | 1216546 | 85 | 448545 | 1219849 |
| 42 | 449749 | 1216614 | 86 | 448283 | 1219844 |
| 43 | 449659 | 1216767 | 87 | 448347 | 1219987 |
| 44 | 449831 | 1216761 | 88 | 448127 | 1219975 |